# កិច្ចសន្ទនាស្ដីពីគោលនយោបាយសាធារណៈ
# លើកកម្ពស់សិទ្ធិរបស់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្ដូរយេនឌ័រ
# ថ្ងៃព្រហស្បតិ៍ ទី៣១ ខែឧសភា ឆ្នាំ២០១៨
# សណ្ឋាគារហ្គ្រីនផាឡេស រាជធានីភ្នំពេញ




## សហការរៀបចំដោយ៖

អង្គការសហគមន៍ឥន្ទធនូកម្ពុជា (RoCK) អង្គការគោលដៅយុត្តិធម៌ (DJ)
អង្គការមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (CCHR) អង្គការថែទាំសុខភាពគ្រួសារកម្ពុជា (RHAC)
អង្គការមីក្រូឥន្ទធនូអន្តរជាតិ (MRI) អង្គការខាន់ណា (KHANA)

## គាំទ្រមូលនិធិ និងបច្ចេកទេសដោយ៖

ភ្នាក់ងារអង្គការសហប្រជាជាតិ UN Women | UNAIDS | OHCHR | UN Volunteers

## គោលបំណង

កិច្ចសន្ទនានេះធ្វើឡើងដើម្បីស្វែងយល់ពីបញ្ហាអាទិភាពរបស់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា ហើយស្វែងរកការគាំទ្រ និងដំណោះស្រាយផ្នែកច្បាប់ និងគោលនយោបាយនៃវិស័យពាក់ព័ន្ធលើបញ្ហាអាទិភាពដែលបានកំណត់ដូចខាងក្រោម៖

១. បញ្ហាផ្នែកច្បាប់ រួមមានអាពាហ៍ពិពាហ៍ភេទដូចគ្នា សុំកូន និងភាពដែលអាចផ្លាស់ប្តូរយេនឌ័រទៅតាមការកំណត់របស់ខ្លួននៅក្នុងឯកសារគតិយុត្ត (អត្តសញ្ញាណបណ្ណ លិខិតឆ្លងដែន និងសៀវភៅគ្រួសារ)។

២. ការរើសអើង និងការផាត់ចេញពីគ្រួសារ និងសាលារៀន។

៣. ឱកាសការងារ និងការរើសអើងនៅកន្លែងការងារ។

## កម្មវិធី

១. សន្ទរកថាចំណាប់អារម្មណ៍ សំណេះសំណាល ប្រកាសបើកកម្មវិធី និងសេចក្តីអំពាវនាវរួម ដោយអធិបតីតំណាងស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា។

២. ការបញ្ចាំងខ្សែវីដេអូខ្លីអំពី និន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ។

៣. ការចែករំលែកបទពិសោធអំពីបញ្ហាជួបប្រទះដោយសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរយេនឌ័រ។

៤. កិច្ចសន្ទនារវាងតំណាងក្រសួងពាក់ព័ន្ធ ជាមួយសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរយេនឌ័រពីទិដ្ឋភាពច្បាប់ និងគោលនយោបាយ និងលទ្ធភាពដោះស្រាយ ។

## លទ្ធផលសរុបរួម

### ការបង្ហាញពីគោលបំណង និងសេចក្តីរំពឹងទុកនៃកម្មវិធី

កញ្ញា លី ពិសី ប្រធានសម្របសម្រួលនៃអង្គការសហគមន៍ឥន្ទធនូកម្ពុជា តំណាងឲ្យស្ថាប័នសហរៀបចំបានបង្ហាញពីគោលបំណង និងសេចក្តីរំពឹងទុកនៃកម្មវិធី ដែលវាគ្មិនតំណាងក្រសួង និងស្ថាប័នរាជរដ្ឋាភិបាលកម្ពុជា និងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា អាចពិភាក្សាគ្នាស្វែងយល់អំពីបញ្ហា ឧបសគ្គ តម្រូវការ ហើយចង្អុរបង្ហាញអំពីលទ្ធភាពដោះស្រាយនូវឧបសគ្គផ្នែកច្បាប់ និងគោលនយោបាយ ជាជំណាក់កាលក្នុងបរិបទប្រទេសកម្ពុជា នៅខណៈដែលបរិយាកាសគាំទ្រ ការទទួលស្គាល់ និងការចេញមុខជាចំហររបស់អ្នកស្រលាញ់ភេទដូចគ្នាកាន់តែមានភាពប្រសើរឡើងជាបន្តបន្ទាប់គួរឲ្យកត់សម្គាល់ និងស្ញប់ស្ញែង។



## មតិសម្តែងនូវចំណាប់អារម្មណ៍




លោកស្រី សារ៉ាហ៍ នីបស៍ (Sarah Knibbs) តំណាងប្រចាំប្រទេសកម្ពុជានៃភ្នាក់ងារអង្គការសហប្រជាជាតិធ្វើការលើកកម្ពស់ស្ត្រី និងសមភាពយេនឌ័រនៅកម្ពុជា បានកោតសរសើរពីការរៀបចំកម្មវិធីថ្ងៃនេះ ដែលមានចូលរួមរៀបចំដោយអង្គការដៃគូ និងសហគមន៍ ក្រោមការគាំទ្រមូលនិធិនិងបច្ចេកទេសដោយភ្នាក់ងារអង្គការសហប្រជាជាតិ បាន និងកំពុងធ្វើការតស៊ូមតិ ដើម្បីឲ្យមានការផ្លាស់ប្តូរគោលនយោបាយនៃការលើកកម្ពស់សមភាពយេនឌ័រ ទាំងសិទ្ធិស្ត្រី និងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នានៅកម្ពុជា ដែលចលនាទាំងពីរត្រូវសហគ្នា ហើយការផ្លាស់ប្តូរនេះមានដំណាក់កាលរបស់វា។ ប្រទេសកម្ពុជាមានវឌ្ឍនភាពជាច្រើនជុំវិញការលើកកម្ពស់សមភាពយេនឌ័រ រួមមានការបញ្ចូលការអប់រំពេញលេញអំពីផ្លូវភេទនៅក្នុងកម្មវិធីសិក្សាជាតិ ដែលក្រសួងអប់រំ យុវជន និងកីឡា

ជាសេនាធិការ។  ទន្ទឹមនឹងនេះវត្តមានអញ្ជើញចូលរួមរបស់មន្ត្រីជាន់ខ្ពស់នៃស្ថាប័នរាជរដ្ឋាភិបាលនៅក្នុងកិច្ចសន្ទនា ដែលជាបង្ហាញនូវការយកចិត្តទុកដាក់។

## មតិស្វាគមន៍ និងបើកកម្មវិធី

ការថ្លែងសន្ទរកថាបើកកម្មវិធី របស់ **ឯកឧត្តម ថាច់ ផែន** រដ្ឋលេខាធិការក្រសួងពត៌មាន តំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមរដ្ឋមន្ត្រី ខៀវ កាញារីទ្ធ៖** ឯកឧត្តមបានមានប្រសាសន៍កោតសរសើរដល់ការរៀបចំអោយមានជំនួបរវាងសមាជិកសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា និងតំណាងក្រសួងស្ថាប័នពាក់ព័ន្ធផ្សេងទៀតផងដែរ។ បញ្ហាអ្នកស្រលាញ់ភេទដូចគ្នាគឺជារឿងថ្មីចំពោះឯកឧត្តមផ្ទាល់ ដែលឯកឧត្តមបានដឹងតិចតួចតាមរយៈសារព័ត៌មានផ្សេងៗ ហើយឯកឧត្តមឆ្លៀតឱកាសនៃកិច្ចសន្ទនានេះក្នុងការស្តាប់ និងសង្កេតដោយយកចិត្តដាក់ ដើម្បីយល់ដឹងកាន់តែទូលំទូលបន្ថែម នៅខណៈពេលឯកឧត្តមទទួលស្គាល់ថា ដំណើរការតស៊ូមតិនៃការផ្លាស់ប្តូរច្បាប់ និងបង្កើតនូវគោលនយោបាយគាំពារទាមទារពេលវេលា។ ឯកឧត្តមបានសន្យាថា នឹងធ្វើរបាយការណ៍បង្ហាញបញ្ហាតម្រូវ និងអនុសាសន៍នានា ជូនចំពោះថ្នាក់ដឹកនាំក្រសួងព័ត៌មានដើម្បីពិចារណា ហើយចូលរួមស្វែងរកការគាំទ្រជាបន្តទៀត។




## ការចាក់បញ្ចាំងខ្សែវីដេអូខ្លីអំពីនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ និងការបង្ហាញយេនឌ័រ

វីដេអូនេះ សហការផលិតដោយ អង្គការសហគមន៍ឥន្ទធនូកម្ពុជា និងអង្គការគោលដៅយុត្តិធម៌។ មានរយៈពេលប្រាំបួននាទី ដោយបង្ហាញនូវ ភេទពីកំណើតរបស់មនុស្សម្នាក់ៗគឺ ភេទស្រី ប្រុស

និងអន្តរភេទ។ អត្តសញ្ញាណ និងការបង្ហាញយេនឌ័រ គឺជាការកំណត់យេនឌ័ររបស់ខ្លួនឯង ដែលពេលខ្លះស្របតាមភេទពីកំណើត និងពេលខ្លះផ្ទុយពីភេទពីកំណើតរបស់ខ្លួន។ ចុងក្រោយនិយាយពីនិន្នាការភេទ គឺជាទំនោរ ឬ អារម្មណ៍នៃសេចក្តីស្រលាញ់របស់បុគ្គលណាម្នាក់ទៅលើបុគ្គលម្នាក់ទៀត ហើយការស្រលាញ់នោះ អាចមានចំពោះមនុស្សដែលមានភេទផ្ទុយគ្នា ឬ ភេទដូចគ្នា ឬ ស្រលាញ់ទាំងពីរភេទ។

## ការចែករំលែកនូវបទពិសោធរបស់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នាផ្ទាល់

**ករណីទី១៖** ការចែករំលែកពីសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរយេនឌ័រ ពីបញ្ហាការរើសអើង និងការផាត់ចេញពីក្រុមគ្រួសារ និងសាលារៀន។ កញ្ញា អ៊ុយ រ៉ាដា មកពីខេត្តបាត់ដំបង ជាអ្នកប្តូរយេនឌ័រពីបុរសទៅស្ត្រី៖

*«ខ្ញុំកើតមកចូលចិត្តតុបតែងខ្លួនជាស្រី ហើយចូលចិត្តលេងកូនក្រមុំតុក្កតា ហើយទទួលបានវាយដំពីសំណាក់បងប្រុស និងការស្តីបន្ទោសពីឪពុកម្តាយ ដែលពួកគាត់បង្ខំអោយខ្ញុំហាត់ពត់លត់ដំធ្វើយ៉ាងអត្តចរិតជាក្មេងប្រុសដូចក្មេងដទៃ។ ថ្ងៃមួយនៅពេលខ្ញុំបានទៅសាលារៀន លោកគ្រូរបស់ខ្ញុំបានមកកាត់សក់របស់ខ្ញុំ ដោយខ្ញុំមិនបានដឹងខ្លួន ហើយខ្ញុំមានអារម្មណ៍ថាខ្មាស់អៀន មិនអាចទទួលយកនូវទង្វើដែលកើតឡើងចំពោះរូបខ្ញុំបាន ទាំងនៅសាលារៀន និងនៅក្នុងក្រុមគ្រួសារ ជាពិសេសគឺខ្ញុំមិនអាចរស់នៅភាពជាខ្លួនឯងពិតប្រាកដ។ កត្តាទាំងនេះបានធ្វើឲ្យខ្ញុំសម្រេចចិត្តឈប់រៀននៅរយៈពេល៦ឆ្នាំក្រោយ ហើយបន្តរស់នៅជាខ្លួនឯងពេញលេញ។ ប៉ុន្តែវាមានភាពលំបាកចំពោះការមិនទទួលស្គាល់។»*






**ករណីទី២៖** ការចែករំលែកពីសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា ពីឱកាសការងារ និងការរើសអើងនៅកន្លែងការងារ ។ លោក រុំ សំបូរ ហៅ ប៊ី ជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស មកពីខេត្តសៀមរាប៖

*«ក្រោយពីខ្ញុំបានចាកចេញពីផ្ទះ ដោយឪពុកម្តាយមិនទទួលស្គាល់នៅពេលខ្ញុំតុបតែងខ្លួន និងតាំងខ្លួនជាបុរស ខ្ញុំបានស្វែងរកការងារ ហើយក៏បានទៅដាក់ពាក្យសុំធ្វើការនៅភោជនីយដ្ឋានមួយ*

*ក្នុងខេត្តសៀមរាប ដែលកំពុងជ្រើសរើសបុគ្គលិកផ្នែករត់តុ។ ថៅកែបានប្រាប់ខ្ញុំថា គេមិនយកខ្ញុំអោយចូលធ្វើការទេដោយសារតែរូបរាងរបស់ខ្ញុំមិនមែនជាមនុស្សស្រីពិតប្រាកដ ហើយកន្លែងគាត់គឺជ្រើសរើសយកតែស្រីសុទ្ធ និងបុរសសុទ្ធ។ ខ្ញុំអន់ចិត្តខ្លាំង ព្រោះខ្ញុំគិតថាអ្វី ពួកគាត់គួរតែទទួលស្គាល់ខ្ញុំជាបុរស ហើយផ្តោតលើសមត្ថភាពជាចម្បង។ ប៉ុន្តែការវិនិច្ឆ័យនេះមិនបានផ្តល់ឱកាសដល់ខ្ញុំបំពេញការងារ និងបង្ហាញសមត្ថភាពខ្លួនទេ។ បន្ទាប់មក ខ្ញុំបានមករកការងារនៅភ្នំពេញ ក្នុងសណ្ឋាគារមួយ ដែលខ្ញុំត្រូវបានទទួលឲ្យចូលធ្វើការ ផ្នែកអ្នករៀបចំបន្ទប់ តែស្ថិតក្រោមលក្ខខណ្ឌអ្នកគ្រប់គ្រងហាមប្រាមមិនអោយខ្ញុំទៅកន្លែងស្ប៉ា ព្រោះដោយសារថាបារម្ភខ្លាចខ្ញុំទៅញ៉ែមនុស្សស្រីនៅកន្លែងស្ប៉ា។ ថ្វីត្បិតតែខ្ញុំបានជោគជ័យ ដោយអ្នកគ្រប់គ្រងទទួលស្គាល់សមត្ថភាពការងាររបស់ខ្ញុំ ប៉ុន្តែខ្ញុំនៅតែមិនយល់ និងមិនអស់ចិត្តចំពោះបម្រាមមកលើរូបខ្ញុំ ខ្លាចទាក់ទងបុគ្គលិកស្ត្រីក្នុងផ្នែកស្ប៉ា នៅខណៈបុគ្គលិកប្រុសដទៃមិនត្រូវបានហាមប្រាម។»*






**ករណីទី៣៖** ការចែករំលែកពីសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា ពីបញ្ហាអាពាហ៍ពិពាហ៍ និងសុំកូន ។ អ្នកនាង ពៅ ដាលីន ជាស្ត្រីស្រលាញ់ភេទដូចគ្នា ហើយដៃគូរបស់គាត់គឺជាស្ត្រីប្តូរយេនឌ័រពីស្ត្រីទៅបុរស មកពីខេត្តព្រះវិហារ៖

*«បច្ចុប្បន្នខ្ញុំមានគ្រួសាររស់នៅជាមួយគ្នាបានរយៈពេលប្រាំឆ្នាំហើយ ហើយខ្ញុំបានសុំកូនប្រុសគេម្នាក់យកមកចិញ្ចឹម។ ខ្ញុំបានដាក់ពាក្យប្តឹងសុំទៅតុលាការហើយ ប៉ុន្តែនីតិវិធីរបស់តុលាការអស់រយៈពេលប្រាំមួយខែហើយ ប៉ុន្តែខ្ញុំនៅមិនទាន់ទទួលបានការឆ្លើយតប និងឯកសារគតិយុត្តបញ្ជាក់ពីសិទ្ធិពេញលេញជាម្តាយឪពុក លើកូនប្រុសចិញ្ចឹមរបស់យើងខ្ញុំនោះទេ។ ហើយថ្មីៗនេះខ្ញុំបានឮដំណឹងមកថា ម្តាយឪពុកបង្កើតរបស់កូនចិញ្ចឹមខ្ញុំនឹងមកយកកូនពីខ្ញុំត្រឡប់ទៅវិញ។ ខ្ញុំមានអារម្មណ៍ពិបាកចិត្តខ្លាំងណាស់ ព្រោះខ្លាចបាត់បង់កូនជាទីស្រលាញ់ ដែលខ្ញុំបានចិញ្ចឹមបីបាច់ថែរក្សា និងថ្នាក់ថ្នមដូចកូនបង្កើតខ្ញុំចឹង។ ម្យ៉ាងទៀត ពួកខ្ញុំមិនអាចធ្វើសំបុត្រកំណើតឲ្យកូនបាន និងគ្មានការអនុញ្ញាតិឲ្យយើងខ្ញុំបញ្ជាក់អំពីសិទ្ធិជាឪពុកម្តាយពេញលេញដូចគ្រួសារភេទផ្ទុយគ្នា។ ភាពយឺតយ៉ាវ និងការមិនទទួលស្គាល់នេះ ធ្វើឲ្យខ្ញុំមានសេចក្តីព្រួយបារម្ភយ៉ាងខ្លាំង ដែលកូនប្រុសខ្ញុំអាចគ្មានលទ្ធភាព*

*ចុះឈ្មោះចូលរៀនទាន់ពេលវេលាដោយសារគេមានអាយុជិតប្រាំឆ្នាំហើយ និងអាចប៉ះពាល់ដល់ការអប់រំ ក៏ដូចជាអនាគតគេផងដែរ។»*

**ករណីទី៤៖** ការចែករំលែកពីសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាពីការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ។ លោក ស៊ុន ភី គឺជាអ្នកប្តូរយេនឌ័រពីស្ត្រីទៅបុរស មកពីខេត្តស្វាយរៀង៖

*«ខ្ញុំបានរស់នៅជាមួយប្រពន្ធខ្ញុំ២៥ឆ្នាំហើយ។ ខ្ញុំមានអាជីពជាអ្នកលេងភ្លេងប្រពៃណីបុរាណ ហើយប្រពន្ធខ្ញុំជាអ្នកចម្រៀងភ្លេងការ។ ពួកខ្ញុំមានកូនស្រីចិញ្ចឹមម្នាក់អាយុ១៦ឆ្នាំ ប៉ុន្តែមកទល់ពេលនេះយើងខ្ញុំមិនទទួលបានការអនុញ្ញាតិឲ្យធ្វើសៀវភៅគ្រួសារបញ្ជាក់ថាយើងជាប្តី និងប្រពន្ធទេ មានការបញ្ជាក់ទទួលស្គាល់ត្រឹមតែជាបងប្អូនប៉ុណ្ណោះ ដោយសារតែការមិនទទួលស្គាល់នូវអត្តសញ្ញាណយេនឌ័ររបស់ខ្ញុំព្រោះវាខុសពីភេទកំណើតខ្ញុំ។ ម្យ៉ាងទៀត កូនស្រីចិញ្ចឹមរបស់យើងខ្ញុំក៏គ្មានសំបុត្រកំណើតដែរ ដោយសារអាជ្ញាធរមិនអាចធ្វើឲ្យបាន ដោយសារយើងទាំងពីរមិនត្រូវបានទទួលស្គាល់ជាឪពុកម្តាយ។ ក្នុងនាមជាឪពុកម្តាយគឺ យើងខ្ញុំមានកតព្វកិច្ចចិញ្ចឹមបីបាច់ ថែរក្សា ការពារនិងបញ្ជូនកូនឲ្យបានចូលរៀនសូត្រ ទទួលបានការអប់រំត្រឹមត្រូវ និងខ្ពង់ខ្ពស់ ដែលអាចកសាងអនាគតដ៏ប្រសើររុងរឿង និងការពារខ្លួនឲ្យរួចផុតពីភាពងាយរងគ្រោះក្នុងសង្គមផ្សេងៗ។ ប៉ុន្តែដោយសារតែគ្មានលិខិតស្នាមស្របតាមផ្លូវច្បាប់ ធ្វើឲ្យកូនស្រីយើងខ្ញុំបាត់បង់ឱកាសទទួលបានការអប់រំ ហើយប៉ះពាល់ដល់សក្តានុពល និងអនាគតគេយ៉ាងធ្ងន់ធ្ងរ។ ខ្ញុំក៏មិនអាចដើរហើរទូលំទូលាយដោសារតែនៅក្នុងអត្តសញ្ញាណបណ្ណរបស់ខ្ញុំបញ្ជាក់ត្រឹមតែភេទពីកំណើតគឺជាស្រី នៅខណៈការកំណត់ និងការបង្ហាញយេនឌ័រខាងក្រៅរបស់ខ្ញុំគឺជាប្រុស ហើយនេះគឺជាបញ្ហាចោទនាពេលអនាគតនៅពេលដែលខ្ញុំចង់ធ្វើលិខិតឆ្លងដែន ហើយមានបំណងធ្វើដំណើរទៅក្រៅប្រទេស។»*

## ទេទិភាពិភាក្សា និងសន្ទនា





វេទិកាពិភាក្សា និងសន្ទនានៃវគ្គទីមួយមានការអញ្ជើញចូលរួមដោយតំណាងក្រសួងកិច្ចការនារី ហើយនិងតំណាងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ជាវាគ្មិនកិត្តិយស ហើយសម្របសម្រួលដោយ **លោកស្រី សេក ស៊ីសុខុម** ប្រធានកម្មវិធីសុខភាពនៃអង្គការរ៉ាក់។




**លោកជំទាវ ញាណ សុចិត្រា អគ្គនាយកនៃអគ្គនាយកដ្ឋានអភិវឌ្ឍន៍សង្គមនៃក្រសួងកិច្ចការនារី៖** អំពីរឿងអ្នកស្រលាញ់ភេទដូចគ្នា គឺមិនមែនជារឿងថ្មីនោះទេ វាកើតមានយូរមកហើយ គ្រាន់តែមិនទាន់មានឱកាសជជែកឲ្យបានទូលំទូលាយ។ នៅក្នុងសៀវភៅសិក្សាអក្សរសាស្ត្រខ្មែរបានសរសេរអំពីធម្មជាតិ និងជីវសាស្ត្ររបស់មនុស្សកើតមកមានភេទបីគឺ ស្រី ប្រុស និងពង្សលិង្គ (មិនមែនប្រុស ឬស្រី) ។ ហើយបន្ទាប់ពីទារកកើតមក ទាមទារឲ្យចុះសំបុត្រកំណើត ដែលភេទរបស់ទារកត្រូវបានកំណត់ដោយគ្រូពេទ្យ និងឪពុកម្តាយ។ នៅក្នុងទិដ្ឋភាពផ្លូវច្បាប់ រាជរដ្ឋាភិបាលបានចុះហត្ថលេខាទទួលស្គាល់អនុសញ្ញាអន្តរជាតិជាច្រើន រាប់បញ្ចូលទាំងសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ និងអនុសញ្ញាស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងស្ត្រីដែលមានន័យថា កម្ពុជាគ្មានច្បាប់រើសអើងជនណាមួយឡើយ។ ប៉ុន្តការអនុវត្តជាក់ស្តែង យើងសង្កេតឃើញមានការរើសអើង ដែលកើតចេញពីគ្រួសារ ដោយសារគ្រួសារនិមួយៗមានសេចក្តីប្រាថ្នា ឬការរំពឹងទុកផ្សេងៗគ្នា។ លោកជំទាវបានអំពាវនាវដល់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នាផ្ទាល់ កុំមានភាពតូចចិត្តចំពោះភាពយឺតយ៉ាវនៃដំណោះស្រាយ ព្រោះថាការវិវត្តរបស់សង្គមអាចផ្លាស់ប្តូរបាន ទាំងការកែប្រែនូវឥរិយាបថ និងទទួលស្គាល់ការពិត។

សម្រាប់ផែនការយុទ្ធសាស្ត្រប្រាំឆ្នាំរបស់ក្រសួងកិច្ចការនារី ក្រសួងធ្វើការប៉ាន់ប្រមាណបញ្ហារបស់ក្រុមដែលងាយរងគ្រោះផ្សេងៗ។ នាពេលថ្មីៗនេះ ក្រសួងកំពុងតែធ្វើកិច្ចពិគ្រោះយោបល់ជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសង្គមស៊ីវិល ដែលធ្វើការពាក់ព័ន្ធនឹងក្រុមជនងាយរងគ្រោះចំនួន៥ ដូចជា ជនពិការ ចាស់ជរា ជនជាតិអ៊ីស្លាម ជនជាតិដើមភាគតិច និងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា ដែលនឹងចេញជាអនុសាសន៍សម្រាប់ការដោះស្រាយនៅក្នុងគោលការណ៍នារីរតនៈទី៥។ បន្ទាប់មក ក្រសួងកិច្ចការនារីនឹងចូលរួមរៀបចំច្បាប់ស្តីពីកិច្ចការពារអំពើហិង្សា ដែលជនរងគ្រោះក្នុង

គ្រួសារ ក្នុងនោះក៏មានសហគមន៍អ្នកស្រលាញ់ភេទដូចគ្នាជាសមាជិកគ្រួសារ ដែលត្រូវទទួលបានការការពារដោយច្បាប់ផងដែរ។

លោកជំទាវបានផ្តល់អនុសាសន៍ ដើម្បីឲ្យការរៀបចំគោលនយោបាយឆ្លើយតបគឺទាមទារនូវការកសាងភស្តុតាង តាមរយៈការសិក្សាស្រាវជ្រាវថ្នាក់ជាតិមួយប្រកបដោយភាពស៊ីជម្រៅអំពីផ្នត់គំនិត ការយល់ឃើញ និងសេចក្តីប្រាថ្នារបស់គ្រួសារ និងសេចក្តីត្រូវការរបស់អ្នកស្រលាញ់ភេទដូចគ្នា បន្ថែមពីការសិក្សាស្រាវជ្រាវដែលអង្គការសហគមន៍ឥន្ទធនូបានធ្វើក្នុងឆ្នាំ២០១៥។ បន្តសកម្មភាពផ្សព្វផ្សាយការយល់ដឹង ចងក្រងបណ្តាញឲ្យបានច្រើន និងរឹងមាំ ដើម្បីជំរុញ ហើយបង្កើនឲ្យមានការទទួលស្គាល់ និងទទួលយក។

**ឯកឧត្តម ជុំ មុំ អនុប្រធាននាយកដ្ឋានផែនការ ស្ថិតិ ការងារ និងនីតិកម្ម ហើយជាសមាជិកគណៈកម្មការយេនឌ័រ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ៖** នៅក្នុងច្បាប់រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការងារនៃព្រះរាជាណាចក្រកម្ពុជា មិនបានចែងរើសអើងទៅលើបុគ្គលភេទទី៣ (អ្នកប្តូរយេនឌ័រ) ហើយមិនបានចែង អំពីសិទ្ធិទទួលបានមុខរបរមួយសមស្របសម្រាប់ភេទទី៣ (អ្នកប្តូរយេនឌ័រ)។ ប៉ុន្តែយើងក៏មិនមានច្បាប់ដាក់ទោស ឬប្រឆាំងអ្នករើសអើងពីភេទទី៣ (អ្នកប្តូរយេនឌ័រ)ដែរ។ ប្រសិនបើនិយោជកបញ្ឈប់ការងារនិយោជិត ដោយសារបុគ្គលិកនោះមានជាភេទទី៣ (អ្នកប្តូរយេនឌ័រ) នោះ ជាកំហុសរបស់និយោជក។ ទោះបីបុគ្គលមានភេទ ឬ យេនឌ័រអ្វី ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្វាគមន៍ និងគាំទ្រជានិច្ច ហើយដើម្បីឆ្លើយតបនឹងតម្រូវការជំនាញវិជ្ជាជីវៈ ការងារ និងសេវាសុខភាព ដោយលោកបានលើកទឹកចិត្តបងប្អូនអ្នកស្រលាញ់ភេទដូចគ្នាទៅទំនាក់ទំនងស្ថាប័នបីនៃ
ក្រសួងការងារ៖ (១) **អគ្គនាយកដ្ឋានបណ្តុះបណ្តាលវិជ្ជាជីវៈ** ផ្តល់វគ្គបណ្តុះបណ្តាលដោយឥតគិតថ្លៃ (២) **ទីភ្នាក់ងារជាតិមុខរបរ និងការងារ** ជួយស្វែងរកការងារដល់អ្នកដែលបានឆ្លងកាត់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និង(៣) **បេឡាជាតិរបបសន្តិសុខសង្គម** ដែលជាកាតព្វកិច្ចរបស់និយោជកក្នុងការបង់ថ្លៃសេវាធានារ៉ាប់រងសុខភាព។ លោកទទួលស្គាល់នូវឧបសគ្គចំពោះកង្វះការទទួលស្គាល់នៃការផ្លាស់ប្តូរយេនឌ័រ សម្រាប់សេចក្តីប្រកាសជ្រើសរើសបុគ្គលិក ទាំងនៅក្នុងវិស័យឯកជន និងសាធារណៈ ដោយកំណត់លក្ខខ័ណ្ឌទទួលយកគឺមានសម្រាប់តែភេទពីកំណើត ផ្អែកលើអត្តសញ្ញាណប័ណ្ណ ដែលជាឯកសារផ្លូវច្បាប់ ហើយបញ្ហានេះលោកមិនទាន់ហ៊ានថានឹងត្រូវដោះស្រាយដោយវិធីណានោះទេ។ អ្វីដែលលោកអាចបញ្ជាក់បានគឺរាល់ការធានានូវលក្ខខណ្ឌការងារសមរម្យ ចំពោះករណីការរើសអើង ការំលោភបំពាន និងការកេងប្រវ័ញ្ចនៅកន្លែងការងារ គឺជាការក្រសួងធ្វើការចុះអធិការកិច្ច ដោយផ្អែកលើយន្តការបី៖ ការបង់សំណងសមរម្យ ការផាកពិន័យ និងបញ្ជូនសំណុំរឿងទៅតុលាការ។

ក្រោមការសម្របសម្រួលដោយ **លោកមេធាវី ហម ស៊ុនរិទ្ធ** នៅក្នុងវេទិកាពិភាក្សាវគ្គទីពីរ ជាមួយ **ឯកឧត្តម យិន ម៉ាលីណា អគ្គនាយករងអគ្គនាយកដ្ឋានអត្តសញ្ញាណកម្ម នៃក្រសួងមហាផ្ទៃ** ឯកឧត្តមបានបង្ហាញនូវចំណាប់អារម្មណ៍ និងការអរគុណចំពោះឱកាសសម្រាប់ឯកឧត្តមក្នុងស្វែងយល់អំពីបញ្ហាប្រឈមរបស់សហគមន៍អ្នកស្រលាញ់ភេទដូចគ្នា តាមរយៈការចែករំលែកនូវរឿងរ៉ាវផ្សេងៗពាក់ព័ន្ធឯកសារអត្រានុកូលដ្ឋាន ដែលកន្លងមកឯកឧត្តមមានភាពឆកល្វែង នៅពេលរៀបចំតាក់តែងច្បាប់។ ឯកឧត្តមរំលឹក ហើយក៏ស្នើឲ្យការជជែកពិភាក្សានេះស្ថិតក្នុងស្មារតីនៃកិច្ចសន្ទនាដើម្បីឈ្វេងយល់ ហើយប្រមើលមើលលទ្ធភាព ឬវិធីសាស្ត្រដោះស្រាយជាជាងការសួរសំណួរ ហើយរំពឹងនូវចម្លើយ ឬដំណោះស្រាយភ្លាមៗ។ ឯកឧត្តមបានឆ្លៀតឱកាសគូសបង្ហាញអំពីទិដ្ឋភាពច្បាប់ ព្រមទាំងភាពស្មុគស្មាញពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ និងសុំកូនរបស់អ្នកស្រលាញ់ភេទដូចគ្នា ព្រមទាំងការទទួលស្គាល់អត្តសញ្ញាណយេនឌ័រ ដូចខាងក្រោម៖



ការទទួលស្គាល់អត្តសញ្ញាណនៅក្នុងសំបុត្រកំណើត វាបញ្ជាក់ពីការទទួលខុសត្រូវផ្លូវច្បាប់។ អត្តសញ្ញាណរបស់មនុស្សម្នាក់ៗ វាជាឯកសារគតិយុត្ត ដែលមាន ***ឈ្មោះ ថ្ងៃខែឆ្នាំកំណើត ភេទ និងទីកន្លែងរស់នៅ***។ កើតមកជាមនុស្សស្រីហើយប្តូរទៅជាមនុស្សប្រុស ឬពីមនុស្សប្រុសប្តូរទៅជាស្រី ក្នុងច្បាប់មានន័យថា បុគ្គលនោះមានចេតនាបិទបាំងអត្តសញ្ញាណខ្លួន។ ហើយភាពស្មុគស្មាញផ្នែកផ្លូវច្បាប់គឺនៅក្នុងករណីមានជនខិលខូចខ្លះបង្ករឿងហេតុ ឬបទល្មើសផ្សេងៗ ហើយពួកគេផ្លាស់ប្តូរអត្តសញ្ញាណភេទរបស់ខ្លួន ដែលសមត្ថកិច្ចពិបាកក្នុងការកំណត់អត្តសញ្ញាណបានច្បាស់លាស់។ មានវិធីមួយដែលបុគ្គលម្នាក់អាចផ្លាស់ប្តូរអត្តសញ្ញាណភេទបាន លុះត្រាតែគាត់ឆ្លងកាត់ការវះកាត់តាមបែបវេជ្ជសាស្ត្រ។ ការប្តូរអត្តសញ្ញាណភេទនៅក្នុងឯកសារផ្លូវច្បាប់នានានឹងត្រូវធ្វើឡើងតាមរយៈការដាក់ពាក្យទៅតុលាការ ដោយតុលាការទទួលស្គាល់ការកំណត់ភេទថ្មីបាន តាមរយៈលិខិតបញ្ជាក់ពីវេជ្ជបណ្ឌិត ឬក្បួនវេជ្ជសាស្ត្រត្រឹមត្រូវថា បុគ្គលម្នាក់នោះបានវះកាត់ប្តូរភេទរួចហើយ។

នៅក្នុងជំនួបពិភាក្សា ក្រុមការងារ ក៏បានឆ្លៀតឱកាសបង្ហាញនូវលទ្ធភាព ឬជម្រើសមួយជូនចំពោះឯកឧត្តម ក្រៅពីដំណើរឆ្លងកាត់ការវះកាត់ប្តូរភេទតាមក្បួនវេជ្ជសាស្ត្រ ដើម្បីឲ្យទទួលបានការទទួលស្គាល់អត្តសញ្ញាណយេនឌ័រនៅក្នុងឯកសារផ្លូវច្បាប់គឺរាល់ទម្រង់ឯកសារអាត្រានុកូលដ្ឋាន និងផ្លូវច្បាប់គួរបន្ថែមប្រអប់ដែលអាចបញ្ជាក់ពីយេនឌ័រនៅក្បែរនឹងប្រអប់បញ្ជាក់ពីភេទ (ឧទាហរណ៍ □ ភេទ □ យេនឌ័រ)។ មានន័យថា បុគ្គលនោះនៅតែតម្រូវឲ្យបញ្ជាក់ពីភេទកំណើតតាមបែបជីវសាស្ត្រ ហើយពួកគេក៏អាចបង្ហាញ ឬបញ្ជាក់ពីអត្តសញ្ញាណយេនឌ័រ ដែលបានកំណត់ផ្ទាល់ខ្លួន ដែលអាចដូច ឬខុសពីភេទពីកំណើតរបស់ខ្លួន។ ធ្វើដូចនេះ បុគ្គលនោះនឹងមិនអាចបន្លំ ឬលាក់បាំងនូវអត្តសញ្ញាណរបស់ខ្លួនពីការចោទប្រកាន់ចំពោះបទល្មើសផ្សេងៗពីអាជ្ញាធររដ្ឋបានទេ ពីព្រោះបុគ្គលនោះមិនអាចកែប្រែភេទពីកំណើតរបស់ខ្លួននៅក្នុងឯកសារផ្លូវច្បាប់បានឡើយ។ ម្យ៉ាងទៀតអាជ្ញាធរមានសមត្ថកិច្ចក៏មិនមានភាពសង្ស័យលើជននោះ ដោយសារតែការកំណត់ និងបង្ហាញអត្តសញ្ញាណយេនឌ័រ តាមរយៈការស្លៀកពាក់ កាត់សក់ខ្លី ទុកសក់វែង និងផាត់មុខមាត់ដែរ។ ចំណុចនេះអាចមានលក្ខណៈឬលទ្ធភាពអាចអនុវត្តន៍បាន នៅពេលដែលបុគ្គលជាច្រើនគ្មានលទ្ធភាពបង់ថ្លៃការវះកាត់ប្តូរភេទតាមបែបវេជ្ជសាស្ត្រត្រឹមត្រូវដែលមានតម្លៃថ្លៃ ហើយខណៈពេលដែលប្រទេសយើង អាចនឹងកំពុងរៀបចំឲ្យមានសេវាកម្មវះកាត់បែបនេះ ដែលទាមទារនូវពេលវេលាយូរ ធនធានហិរញ្ញវត្ថុច្រើន និងធនធានមនុស្សគ្រប់គ្រាន់ជាពិសេសគ្រូពេទ្យឯកទេសច្បាស់លាស់។ ឯកឧត្តមក៏បានទទួលយកយោបល់នៃជម្រើសនេះទៅពិចារណា និងពិភាក្សាជាមួយអ្នកពាក់ព័ន្ធដទៃទៀត ក្នុងដំណើរនៃការសិក្សាស្វែងយល់បន្ថែមលើបញ្ហាដ៏ស្មុគស្មាញផ្នែកច្បាប់នេះ។

ចំពោះពាក្យថា «ប្តី» មានន័យថាជា «បុរស» ហើយ «ប្រពន្ធ» មានន័យថា «ស្ត្រី» នៅក្នុងសំបុត្រអាពាហ៍ពិពាហ៍។ ជម្រើសមួយនៃការប្រើប្រាស់ពាក្យជំនួស ដោយមិនរឹតត្បិតអំពីអត្តសញ្ញាណភេទពីកំណើត ហើយអនុញ្ញាតឲ្យទទួលស្គាល់នូវការកំណត់អត្តសញ្ញាណយេនឌ័រផ្សេងបានគឺពាក្យថា «ដៃគូ»។ នាពេលបច្ចុប្បន្នក្រសួងមហាផ្ទៃ ដោយមានឯកឧត្តម និងក្រុមការងារ ធ្វើការសហការជាមួយក្រសួងយុត្តិធម៌ ក្រោមការដឹកនាំដោយ **លោកជំទាវ ច័ន្ទ សុធាវី** កំពុងរួមគ្នាដើម្បីរៀបចំ **សេចក្តីព្រាងច្បាប់ស្តីពីអាត្រានុកូលដ្ឋាន** ដែលបញ្ហាដែលបានលើកខាងលើពិតជាមានសារសំខាន់សម្រាប់យកទៅពិចារណា។ ចំណុចមួយដែលត្រូវបញ្ជាក់ឲ្យបានច្បាស់នោះគឺថាតើយើងចង់បានការទទួលស្គាល់រួមក្នុងភាពជាពលរដ្ឋ ឬការទទួលស្គាល់ដាច់ដោយឡែកដោយផ្តោតលើតែអ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរយេនឌ័រ ដែលការទទួលស្គាល់ដាច់ដោយឡែកទាមទារឲ្យផ្លាស់ប្តូរពាក្យ «ប្តីប្រពន្ធ» ពីព្រោះពាក្យនេះគឺជាឧបសគ្គ។ ហើយការផ្លាស់ប្តូរដ៏ធំនេះតម្រូវឲ្យមានការធ្វើវិសោធនកម្ម

ច្បាប់រដ្ឋធម្មនុញ្ញ និងក្រមរដ្ឋប្បវេណី ហើយបន្ថែមពីនេះ វាក៏ទាក់ទិននឹងការប្រើប្រាស់នាមត្រកូលខាងប្តី ឬប្រពន្ធផងដែរ។

ការផ្លាស់ប្តូរច្បាប់អាចធ្វើទៅបានទាមទារកត្តាសំខាន់ៗពាក់ព័ន្ធគ្នារួមមាន៖(១) ឆន្ទៈរបស់អ្នកនយោបាយ (២) សម្លេងរបស់សហគមន៍ក្នុងការធ្វើឲ្យអ្នកនយោបាយយល់ និងទទួលយកថាពិតជាតម្រូវការដ៏មានសារៈសំខាន់(៣) អ្នកបច្ចេកទេសធ្វើសេចក្តីព្រាងនូវនីតិវិធីជាជំនួយការដើម្បីឈានដល់ (៤)រាជរដ្ឋាភិបាល និងសមាជិកសភា ព្រឹទ្ធសភា ធ្វើការត្រួតពិនិត្យ។

នៅខណៈពេលដែលកំពុងទាមទារឲ្យមានច្បាប់ ទទួលស្គាល់អាពាហ៍ពិពាហ៍អ្នកស្រលាញ់ភេទដូចគ្នាឯកឧត្តមបានបញ្ជាក់ផងដែរថា មកដល់បច្ចុប្បន្នអ្នកស្រលាញ់ភេទផ្ទុយគ្នា (ប្តីប្រពន្ធ) បានចុះសំបុត្រអាពាហ៍ពិពាហ៍ប្រមាណជា២៩ភាគរយប៉ុណ្ណោះ មានន័យថា ៧១ភាគរយទៀតគឺមិនបានចុះ ហើយអត្រានៃការលែងលះមានដល់ទៅ៤៥ភាគរយក្នុងចំណោមអ្នកដែលបានរៀបការនៅអាយុ២៥ឆ្នាំ។ ដែលទាំងនេះគឺបង្ហាញអំពីស្ថិតិ ប្រសិទ្ធិភាព និងការឆ្លើយតបនៃច្បាប់ ព្រមទាំងគោលនយោបាយ។

សុំកូនមានពីរ សុំកូនធម្មតា អ្នកណាក៏អាចធ្វើបានដែរ និងសុំកូនពេញលេញ កុមារត្រូវតែមានអាយុក្រោម៨ឆ្នាំ មានសំបុត្រអាពាហ៍ពិពាហ៍ស្របច្បាប់ ហើយសុំកូនត្រូវតែជាសេចក្តីសម្រេចរបស់តុលាការ។ ប្រសិនបើមានស្ថិតិ ពីអ្នកស្រលាញ់ភេទដូចគ្នាកាន់តែច្រើនអាចជួយខ្ញុំបានក្នុងការពិភាក្សាក្នុងការរៀបំបង្កើតនូវគោលនយោបាយ និងច្បាប់ថ្មី។

## សន្ទរកថាបូកសរុបលទ្ធផលនៃកិច្ចពិភាក្សា និងជម្រុញការអនុវត្តផែនការបន្ត

**ឯកឧត្តម កេត្តា អ៊ិន សមាជិកគណៈកម្មាធិការសិទ្ធិមនុស្សកម្ពុជា** និងជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តមប្រធាន កែវ រ៉េមី** បានថ្លែងសន្ទរកថាបូកសរុបលទ្ធផលនៃកិច្ចសន្ទនាស្តីពីគោលនយោបាយសាធារណៈស្តីពីការលើកកម្ពស់សិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា និងអ្នកប្តូរយេនឌ័រដែលមានខ្លឹមសារដូចខាងក្រោម៖

សន្តិភាពរបស់ប្រទេសជាតិគឺជាមូលដ្ឋានគ្រឹះ ឬចំណុចស្នូល នៃអ្វីៗទាំងអស់ ដែលសម្រាប់កម្ពុជារាជរដ្ឋាភិបាលក្រោមការដឹកនាំដ៏ឈ្លាសវៃរបស់សម្តេចតេជោនាយករដ្ឋមន្ត្រី ធានាបាននូវសុខសន្តិភាពជាងបីទសវត្សរ៍។ ហើយបើយើងនិយាយអំពីការអនុវត្តនូវគោលនយោបាយ ច្បាប់ ដើម្បីគោរព និងការពារសិទ្ធិមនុស្ស រាប់បញ្ចូលទាំងសិទ្ធិអ្នកស្រលាញ់ភេទដូចគ្នា គឺកម្ពុជាបានធ្វើយ៉ាងល្អប្រសើរ ហើយអាចនិយាយបានថាមានបរិយាកាស និងលក្ខណៈប្រសើរជាងបណ្តាប្រទេសដទៃទៀតនៅក្នុងតំបន់អាស៊ីអាគ្នេយ៍ ឬអាស៊ានផងដែរ។ យើងសង្កេតឃើញប្រទេសខ្លះគ្រាន់តែឃើញអ្នកប្តូរយេនឌ័រគឺមានការវាយប្រហារ ប្រើអំពើហិង្សា និងប្រើទារុណកម្ម និងទុក្ខទោស ទៅលើអ្នកប្តូរយេនឌ័រទៀត

ផង។ ដើម្បីធ្វើអោយមានការរស់នៅប្រកបដោយសុខសន្តិភាព នៅកម្ពុជាទាំងផ្លូវគតិយុត្ត និងផ្លូវអារម្មណ៍ យើងត្រូវដើរតាមប្រការទាំងបួនគឺ៖(១) ធ្វើខ្លួនឯងជាបុគ្គលល្អ ដែលមិនរំលោភបំពានច្បាប់ (២) ត្រូវក្លាហាន ហ៊ានចេញមុខជាចំហរ ទទួលស្គាល់ខ្លួនឯង (៣) ការទំនាក់ទំនង និង(៤) កិច្ចសហប្រតិបត្តិការ។






ដូច្នេះ ខ្ញុំសូមលើកទឹកចិត្តឲ្យភាគីពាក់ព័ន្ធបន្តនូវទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការ យកលទ្ធផលនៃកិច្ចសន្ទនាផុសផុលរវាងសហគមន៍អ្នកស្រលាញ់ភេទដូចគ្នា អ្នកប្តូរយេនឌ័រ បណ្តាអង្គការមិនមែនរដ្ឋាភិបាល អង្គការសហប្រជាជាតិ ជាមួយតំណាងក្រសួងស្ថាប័នរបស់រាជរដ្ឋាភិបាលកម្ពុជា ដើម្បីស្វែងរកដំណោះស្រាយផ្នែកច្បាប់ និងគោលនយោបាយ និងជាដំណាក់កាលដ៏សមស្រប។

*«ការប្រាស្រ័យទាក់ទងគ្នា គឺជារឿងសំខាន់ណាស់មិនថាប្រជាពលរដ្ឋ មិនថាអង្គការសង្គមស៊ីវិល មិនថារាជរដ្ឋាភិបាល នោះទេ គឺសុទ្ធតែត្រូវការ ទំនាក់ទំនងគ្នាទៅវិញទៅមក។ ដំណើរការមួយនៃការផ្លាស់ប្តូរអាចជោគជ័យ គឺត្រូវការទំនាក់ទំនងជាចាំបាច់។»*

**-ចប់-**